**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៥៨ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតដែនជម្រកសត្វព្រៃតាតៃ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

### មាត្រា១ .-

ត្រូវបានបង្កើតដែនជម្រកសត្វព្រៃតាតៃ ដែលមានផ្ទៃដីទំហំ ១៤៤.២៧៥(មួយសែនបួនម៉ឺនបួនពាន់ពីររយចិតសិបប្រាំ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា(Datum: WGS1984) ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y |
| 1 | 333655 | 1237644 | 8 | 320129 | 1279197 | 15 | 279635 | 1285319 |
| 2 | 334628 | 1250482 | 9 | 313903 | 1290340 | 16 | 283583 | 1284835 |
| 3 | 333522 | 1251795 | 10 | 308904 | 1286907 | 17 | 287071 | 1283566 |
| 4 | 340217 | 1253730 | 11 | 290700 | 1296846 | 18 | 288602 | 1280862 |
| 5 | 337961 | 1273556 | 12 | 284697 | 1297036 | 19 | 297469 | 1270259 |
| 6 | 326102 | 1273573 | 13 | 280676 | 1294877 | 20 | 306046 | 1259132 |
| 7 | 311777 | 1267239 | 14 | 277886 | 1291385 | | | |

### មាត្រា២ .-

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី ព្រមទាំងធានាឱ្យមានការបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ រុក្ខជាតិ និងជីវៈចម្រុះ
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

### មាត្រា៣ .-

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងដែនជម្រកសត្វព្រៃតាតៃ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលដែនដីខេត្តកោះកុង ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។



www.pheakdeylaw.com

**មាត្រា៤ .-**

អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៤ ស្ដីពីការបង្កើតតំបន់ព្រៃការពារ សំរាប់អភិរក្សជីវចំរុះ ការពារប្រេករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្ដារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រ សត្វព្រៃខេត្តកោះកុង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

## ផែនទី ដែនជម្រកសត្វព្រៃ តាតៃ ស្ថិតក្នុងខេត្តកោះកុង

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៦




និយាមការគោល

| ID | X_Coord | Y_Coord |
|---|---|---|
| 1 | 333655 | 1237644 |
| 2 | 334628 | 1250482 |
| 3 | 333522 | 1251795 |
| 4 | 340217 | 1253730 |
| 5 | 337961 | 1273556 |
| 6 | 326102 | 1273573 |
| 7 | 311777 | 1267239 |
| 8 | 320129 | 1279197 |
| 9 | 313903 | 1290340 |
| 10 | 308904 | 1286907 |
| 11 | 290700 | 1296846 |
| 12 | 284697 | 1297036 |
| 13 | 280676 | 1294877 |
| 14 | 277886 | 1291385 |
| 15 | 279635 | 1285319 |
| 16 | 283583 | 1284835 |
| 17 | 287071 | 1283566 |
| 18 | 288602 | 1280862 |
| 19 | 297469 | 1270259 |
| 20 | 306046 | 1259132 |




**សញ្ញាសម្គាល់**

- ចំណុចគោល
- ទីរួមខេត្ត
- ព្រំប្រទល់ប្រទេស
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ស្រុក
- ផ្លូវ
- តំបន់ការពារធម្មជាតិ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃតាតៃ

**គម្របព្រៃឈើ ឆ្នាំ២០១៥**

- ព្រៃស្រោង
- ព្រៃកម្លោង
- ព្រៃឫស្សី
- ព្រៃកោងកាង
- វាលស្មៅ
- ទន្លេ បឹង

Map Coordinate System:
Unit: meter
System: UTM, Zone 48
Datum: WGS 1984

0 5 10 km

ផ្ទៃដី ដែនជម្រកសត្វព្រៃតាតៃ សរុប ១៤៤ ២៧៥ ហិកតា

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៦

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

*បញ្ជាក់៖ ខ្សែបន្ទាត់ព្រំដែននៃផែនទីនេះពុំមានតម្លៃផ្លូវការជាអន្តរជាតិឡើយ។*

www.pheakdeylaw.com